សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌលេខ: ៧៧០
ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៧
សាលក្រមលេខ: ៧០"ខ"
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបាត់ដំបងនៅថ្ងៃទី ១០ ខែ ឆ្នាំ២០១២ និងប្រកាសសាលក្រម នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សា

កញ្ញា [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីតុលាការព្រហ្មទណ្ឌ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៧៧០ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ភេទស្រី អាយុ ៤៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបររក ធ្វើស្រែ កើតនៅភូមិ [redacted] សាសនាព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី១០ចាស់ ទីលំនៅសព្វថ្ងៃភូមិ [redacted] ប្តីឈ្មោះ [redacted] មានកូន ០៥នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) ទោសពីមុន គ្មាន ក្រៅឃុំ ។

២-ឈ្មោះ [redacted] វុឌ្ឍី ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបររកស៊ី ធ្វើ កើតនៅភូមិ [redacted] សាសនាព្រះពុទ្ធ កំរិតវប្បធម៌ សាលាបាលី ទីលំនៅសព្វថ្ងៃភូមិ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន ០៦នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លា ទោសពីមុន គ្មាន ក្រៅឃុំ ។

មានលោក [redacted] តារា ជាមេធាវីការពារជនជាប់ចោទ ។

ពីបទ ប្លន់ បញ្ញត្តិមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ប្រព្រឹត្តិនៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី០ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

ស្កេនជាមួយ CamScanner

ឈ្មោះ [redacted] សុផាន ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ [redacted] ។

ទីលំនៅ [redacted]

ប្តឹងទាមទារសំណងអន្តរាយចំនួន ៧០.០០០ បាត (ចិតសិបពាន់បាត) ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ ជនជាប់ចោទឈ្មោះ [redacted] ហឿ និងឈ្មោះ
បាននាំប្រជាជនចំនួន ២០នាក់ គ្មានសារតា បររទេះគោចំនួន ១២ គ្រឿង ទៅច្រូតយកផល
ឈ្មោះ [redacted] ទាឡេង ស្ថិតនៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង អ
១ហិចតាកន្លះ ដឹកយកមកទុកដាក់នៅផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] ហឿ ដល់ថ្ងៃទី
វិច្ឆិកា ឆ្នាំ២០០៧ ជនជាប់ចោទដដែល ដឹកនាំប្រជាជនចំនួន ២២នាក់ បររទេះគោចំនួន
បានទៅច្រូតយកផលស្រូវរបស់ឈ្មោះ [redacted] ទាឡេង ដែលមានឈ្មោះ [redacted] សុផាន ជាអ្នក
ខុសត្រូវ ស្ថិតនៅភូមិគុយវែង ឃុំព្រះផុស អស់ចំនួន ១ហិចតាកន្លះទៀត ដឹកជញ្ជូនយក
ផ្ទះជនជាប់ចោទឈ្មោះ [redacted] វុឌ្ឍី ហើយក្នុងការច្រូតយកផលស្រូវនេះ សមត្ថកិច្ចទៅរាំង
មិនស្តាប់ដែរ ។

-តាមរបាយការណ៍លេខ: ១០៦ ប.ប.យ.ព.ផ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០
នាយប៉ុស្តិ៍នគរបាលព្រះផុស បានបញ្ជាក់ថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ ម៉ោង ៨ព្រឹ
[redacted] ហឿ និងឈ្មោះ [redacted] វុឌ្ឍី បានដឹកនាំប្រជាជនចំនួន ២០នាក់ មានរទេះគោចំនួន ២០
-គ្នាទៅលួចច្រូតយកផលស្រូវនៅភូមិតាខោ ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង រ
[redacted] ទាឡេង អស់ចំនួន ១ហិចតាកន្លះ ។

- តាមរបាយការណ៍ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់អធិការនគរ
ក្រឡ បានបញ្ជាក់ថា: នៅព្រឹកថ្ងៃទី០២ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ឈ្មោះ [redacted] ហឿ
[redacted] វុឌ្ឍី បានដឹកនាំប្រជាជន ២០នាក់ ទៅច្រូតយកផលស្រូវរបស់ឈ្មោះ [redacted] ទាឡេង នៅ
ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង អស់ចំនួន ៣ហិចតា ។

## នៅចំពោះមុខនាពេលសវនាការ

- ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ជាជនជាប់ចោទ បានឆ្លើយបញ្ជាក់ថា: នៅ
វិច្ឆិកា ឆ្នាំ២០០៧ ខ្លួនពិតជាបានប្រវាស់ដៃជាមួយប្រជាជននាំគ្នាទៅច្រូតយកផលស្រូ
លើដី ស្ថិតនៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង មែន ព្រោះស្រូ
ខ្លួន ដែលព្រួសតាំងពីខែកក្កដា ឆ្នាំ២០០៧ មកម្ល៉េះ ហើយពេលច្រូតកាត់រួចបាន
ហាលនៅផ្ទះឈ្មោះ [redacted] វុឌ្ឍី ។

-ឈ្មោះ [redacted] វុឌ្ឍី ជាជនជាប់ចោទបានឆ្លើយថា: នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ
ពិតជាទៅជួយច្រូតផលស្រូវឲ្យឈ្មោះ [redacted] ហឿ ពិតប្រាកដមែន ដោយប្រវាស់ដៃគ្នា
ស្រូវរួច គាត់មកជួយច្រូតស្រូវឲ្យខ្លួនវិញ ហើយស្រូវដែលច្រូតបានមកគឺឈ្មោះ ចាន់ ហឿ
នៅផ្ទះរបស់ខ្លួន ព្រោះផ្ទះគាត់ មានទីធ្លាចង្អៀតពិបាកក្នុងការហាលស្រូវ ចំពោះផលប្រ

ស្កេនជាមួយ CamScanner

ពុំបានទេ ។

- ឈ្មោះ [redacted] សុផាន ហៅ វិត ជាដើមបណ្ដឹង បានឆ្លើយបញ្ជាក់ថា: ខ្លួនជាអ្នក
ការខុសត្រូវនៅការដ្ឋានរបស់ឈ្មោះ [redacted] ទាឡេង ស្ថិតនៅភូមិព្រះផុស ឃុំគុយវែង ស្រុកគាស់
ខេត្តបាត់ដំបង ហើយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឈ្មោះ [redacted] ហឿ និងឈ្មោះ [redacted] វន្នី បា
ប្រជាជន២២នាក់ មានរទេះគោ១២គ្រឿង មកច្រូតយកផលស្រូវរបស់ឈ្មោះ លឹម ទាឡេង អស់
៣ហិចតា ហើយស្រូវនេះ ខ្លួនបានភ្ជួរព្រួសតាំងពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៧ មកម្ល៉េះ នៅពេល
បានរដឹកដឹកជញ្ជូនយកទៅទុកនៅផ្ទះរបស់ឈ្មោះ [redacted] ហឿ និងឈ្មោះ [redacted] វន្នី ទាំងអស់ នៅក្នុង
ហេតុនេះខ្លួនប្ដឹងទាមទារសំណងអន្តរាយចំនួន ៧០.០០០ បាត ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា :

នៅថ្ងៃទី០២ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅភូមិគុយវែង ឃុំព្រះផុស ស្រុក
ក្រឡ ខេត្តបាត់ដំបង ពិតជាមានអំពើល្មើសលួចច្រូតយកផលស្រូវរបស់ឈ្មោះ [redacted] ទាឡេង
ចំនួន ៣ហិចតា ពិតប្រាកដមែន ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ហឿ ,ឈ្មោះ [redacted] វន្នី
និងសកម្មភាពរបស់ជនជាប់ចោទក្នុងការប្រើហឹង្សាគំរាមដល់អ្នកគ្រប់គ្រង និងសមត្ថកិច្ច ក្នុងបំ
យកទ្រព្យអ្នកដទៃជាប្រយោជន៍របស់ខ្លួនជាការប្រព្រឹត្តិល្មើសព្រហ្មទណ្ឌក្នុងបទប្លន់ បំពាននឹងម
៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

តម្កល់ការចោទប្រកាន់នៅដដែលគ្មានការកែប្រែ និងសុំឲ្យតុលាការផ្ដន្ទាទោស
ជាប់ចោទទៅតាមច្បាប់ ។

មេធាវីការពារជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា

ស្នើសុំលោកចៅក្រមមេត្តាលើកលែងចោទប្រកាន់លើកូនក្ដីខ្លួនឈ្មោះ [redacted] វន្នី
បន្ធូរបន្ថយទោសលើឈ្មោះ [redacted] ហឿ និងកែប្រែបទចោទពីបទ ប្លន់ តាមមាត្រា ៦ នៃច្បាប់
ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាវិញ

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹង
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា:**

- នៅថ្ងៃទី០២ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅភូមិគុយវែង ឃុំព្រះផុស ស្រុក
ក្រឡ ខេត្តបាត់ដំបង មានអំពើហឹង្សាគំរាមអ្នកគ្រប់គ្រង និងសមត្ថកិច្ចច្រូតយកផលស្រូវរបស់
[redacted] ទាឡេង អស់ចំនួន ៣ហិចតា ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ហឿ ហៅ ម៉ៅ
ឈ្មោះ [redacted] វន្នី ។

- តាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបាត់ដំបង និង

ស្កេនជាមួយ CamScanner

ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ បានចោទប្រកាន់លើឈ្មោះ
និងឈ្មោះ [redacted] វុឌ្ឍី ភេទប្រុស ពីបទ ប្លន់ ប្រព្រឹត្តិនៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ
ដំបង កាលពីថ្ងៃទី០២ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និ
ទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- តាមចម្លើយរបស់ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ជាជនជាប់ចោទថា: នៅថ្ងៃទី០២
០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ខ្លួនពិតជាបាននាំគ្នាទៅច្រូតយកផលស្រូវ ហើយយកមកគរទុកនៅផ្ទ
ខ្លួនពិតមែន ចម្លើយនេះអាចពិចារណាបាន តែការអះអាងថាស្រូវនោះជារបស់ខ្លួនជាអ្នកព្រួ
ដាំនៅលើដីរបស់ខ្លួនតាំងពីខែកក្កដា ឆ្នាំ២០០៧ តុលាការមិនអាចពិចារណាបានឡើយ ដោ
អះអាងនេះពុំមានភស្តុតាងត្រឹមត្រូវទៅតាមច្បាប់ ។

- តាមចម្លើយរបស់ឈ្មោះ [redacted] វុឌ្ឍី ជាជនជាប់ចោទ ពេលសវនាការ បានអះអ
នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៧ ពិតជាបានទៅជួយច្រូតស្រូវឲ្យឈ្មោះ [redacted] ហឿ ហើយឈ្មោ
ហឿ ផ្ញើស្រូវទុកនៅផ្ទះខ្លួន ដោយគ្មានកន្លែងហាលដំយកផល ដោយពុំដឹងថាឈ្មោះនេះទៅ
គេទេ ព្រោះទៅជាមួយបងប្អូនប្រជាជនច្រើននាក់ ស្មានតែស្រូវដែលគាត់ដាំលើដីគាត់ ចម្
អាចពិចារណាបាន។

- តាមការអះអាងរបស់ឈ្មោះ [redacted] សុផាន ហៅ វុិត ជាដើមបណ្តឹងថា: នៅ
០២ ខែវិច្ឆិកា ឆ្នាំ២០០៧ ម៉ោង ៨ ឈ្មោះ ចាន់ ហឿ បាននាំប្រជាជនជាច្រើននាក់ និងរទេះ១
ទៅច្រូតផលស្រូវរបស់ឈ្មោះ [redacted] ទាឡេង អស់ចំនួន ០៣ហិចតា នៅភូមិគុយវែង ឃុំព្រះផុ
គាស់ក្រឡ ខេត្តបាត់ដំបង ហើយដឹកយកមកទុកនៅផ្ទះឈ្មោះ [redacted] វុឌ្ឍី ពេលខ្លួនប្តឹង គ
ស្តាប់អ្នកណាទេ ស្តាប់តែព្រះរាជអាជ្ញាប៉ុណ្ណោះ ពេលកំលាំងសមត្ថកិច្ចមកដល់ក៏ក្រឡ
អាចពិចារណាបាន ។

- តាមចម្លើយជនជាប់ចោទ,ចម្លើយដើមបណ្តឹង,របាយការណ៍ស៊ើបអង្កេតរ
នគរបាលយុត្តិធម៌ និងរូបថត ជាភស្តុតាងដាក់បន្ទុកមានលក្ខណៈគ្រប់គ្រាន់ និងស៊ីសង្វា
កំណត់បានថា នៅថ្ងៃទី០២ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ពិត
ប្រជាជនជាច្រើននាក់ ប្រដាប់ដោយកាំបិត,កណ្តៀវ និងបររទេះគោចំនួន ១២ គ្រឿង ទ
ផលស្រូវរបស់ឈ្មោះ [redacted] ទាឡេង នៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្ត
ហើយពេលធ្វើសកម្មភាពច្រូតកាត់ឈ្មោះ [redacted] សុផាន សហការជាមួយសមត្ថកិច្ចចុះទៅរ
ឃាត់ ត្រូវឈ្មោះ [redacted] ហឿ គំរាម ហើយប្រមាថមើលងាយ ដោយពាក្យសម្តី ហើយដឹក
ផលស្រូវដែលច្រូតកាត់បានយកទុកនៅផ្ទះឈ្មោះ [redacted] វុឌ្ឍី ហាលដំយកប្រយោជន៍ផ្ទាល់ខ្លួ

- ចំណែកឯឈ្មោះ [redacted] វុឌ្ឍី បានបញ្ជាក់ថា ខ្លួនគ្រាន់តែឲ្យផ្ទះដាក់ស្រូវ ដោ
ឈ្មោះ [redacted] ហឿ ច្រូតរបស់អ្នកណាឡើយ នោះពុំមានធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted]
គប្បីឲ្យរួចផុតពីការចោទប្រកាន់ ។

- ក្នុងពេលប្រព្រឹត្តិជនជាប់ចោទឈ្មោះ [redacted] ហឿ មានស្មារតីគ្រប់គ្រាន់ អ
ពីអំពើដែលខ្លួនប្រព្រឹត្តិ តែនៅតែប្រព្រឹត្តិបានសម្រេចតាមបំណងរបស់ខ្លួនទៀត ។

ស្កេនជាមួយ CamScanner

...បកម្មភាពរបស់ជនជាប់ចោទឈ្មោះ ចាន់ ហៀ ក្នុងការប្រមូលកំ ច្រូតកាត់យកផលល្វះ ដោយហឹង្សារបស់អ្នកដទៃយកមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ជាកា យកទ្រព្យអ្នកដទៃដោយចេតនាទុច្ចរិត ចំណែកអ្នកផ្សេង គ្រាន់តែទៅ ស្មានតែជាទ្រព្យរប [redacted] ហៀ ដោយអ្នកផ្សេងគ្មានចេតនាឡើយ ។

- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហៀ ហៅ ម៉ៅ មិនមែនជាអំពើប្លន់ទេ ជា គប្បីកែប្រែមកមាត្រា ៣៥៣ និង៣៥៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាវិញ ។

- គ្មានភ័ស្តុតាង និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វុឌ្ឍី ភេទប្រុស អាយ ពីបទ ប្លន់ ប្រព្រឹត្តិនៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពី និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- មានភ័ស្តុតាង និងមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហៀ ហៅ ម៉ៅ ពីរ ប្រព្រឹត្តិនៅគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី០២ និងទី០៣ ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង៣៥៦ ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នាពេលសវនាការ សន្និដ្ឋានពីភ័ស្តុតា បន្ទុកលើជនជាប់ចោទ និងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ មានលក្ខណៈ លាស់ អាចឲ្យតុលាការពិចារណាបាន ។

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ សន្និដ្ឋានថាពីភ័ស្តុតាងដោះ លើជនជាប់ចោទ មានលក្ខណៈមិនច្បាស់លាស់ មិនអាចឲ្យតុលាការពិចារណាបានទេ ។

- ការប្តឹងទាមទារសំណងអន្តរាយរបស់ដើមបណ្តឹងចំនួន ៧០.០០០ បាត (ប្រាំពី បាត) មានលក្ខណៈត្រឹមត្រូវ អាចឲ្យតុលាការពិចារណាបាន ។

- ជនជាប់ចោទឈ្មោះ [redacted] ហៀ ទើបប្រព្រឹត្តិកំហុសជាលើកដំបូង ហើយជាបទម ចំណុចនេះតុលាការគប្បីពិចារណា ។

## ហេតុដូច្នេះសម្រេច

* * * *

I- ឲ្យឈ្មោះ [redacted] វុឌ្ឍី ភេទប្រុស អាយុ ៨៦ឆ្នាំ រួចផុតការចោទប្រកាន់ពីបទ ប្រព្រឹត្តិនៅភូមិគុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី០២ និងទី០៣ វិច្ឆិកា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថា ទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

II- កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ហៀ ហៅ ម៉ៅ ពីបទ ប្លន់ តាមមាត្រា ៦ ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកបទ លួច តាមមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រ ទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

III- ផ្តន្ទាទោសលើឈ្មោះ [redacted] ហៀ ហៅ ម៉ៅ ភេទស្រី អាយុ ៤៩ឆ្នាំ ដាក់ពន្ធនាគ

ស្កេនជាមួយ CamScanner

ទោសនេះត្រូវព្យួរទាំងអស់ក្នុងរយៈពេលសាកល្បង ០៣ឆ្នាំ (បីឆ្នាំ) ។

ពីបទ លួច ប្រព្រឹត្តិនៅភូមិគុយវែង ឃុំព្រះធុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាល
ពីថ្ងៃទី០២ និងទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឡើងនិងផ្តន្ទាទោសតាម
មាត្រា ៣៥៣ ,៣៥៦ ,១០៧,១១៧ និង១១៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

IV- បង្គាប់ឲ្យឈ្មោះ [redacted] ហៀ ហៅ ម៉ៅ សងសំណងការខូចខាត និងជម្ងឺចិត្តចំ
៦.០០០.០០០ ៛ (ប្រាំមួយលានរៀល) ឲ្យទៅឈ្មោះ [redacted] សុផាន ជាតំណាងដើមបណ្តឹងរដ្ឋប្បវេ
ឈ្មោះ លឹម ទារឡេង គិតពីពេលសាលក្រមចូលជាស្ថាពរ ការទាមទារលើសពីនេះបដិសេធចោល

III- សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោ
ឈ្មោះ [redacted] វ៉ៃ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហៀ ហៅ ម៉ៅ និង ដើមបណ្តឹងរដ្ឋប្បវេណី
ទុករយៈពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា
[redacted]

ចៅក្រមប្រឹក្សា
ហត្ថលេខា និងត្រា
[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជំរះ
ហត្ថលេខា និងត្រា
[redacted]

.................................................................................................

បានចម្លងត្រឹមត្រូវចេញពីសាលាក្រមដើម
បាត់ដំបង ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២
ក្រឡាបញ្ជី
[redacted]

បានឃើញ
បាត់ដំបង,ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២
ប្រធានក្រុមប្រឹក្សាជំនុំជំរះ
[redacted]

ស្កេនជាមួយ CamScanner